# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តសៀមរាប**

**សាលក្រមព្រហ្មទណ្ឌ**

លេខ ០៨(ញ)/១៦៩

ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ ២០២២

-សំណុំរឿងព្រហ្មទណ្ឌលេខ ៦៧៥ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០២១

-សំណុំរឿងស៊ើបសួរលេខ ៦០៧ ចុះថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ ២០២១

-សំណុំរឿងជំនុំជម្រះលេខ ១២៩ ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០២២

# សាលក្រម
## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

| | |
|---|---|
| កាលបរិច្ឆេទនៃសវនាការអជាសាធារណៈ | ៖ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០២២ |
| សាលសវនាការ និងពេលវេលា | ៖សាលលេខ ខ១ នៅម៉ោង៨:០នាទីព្រឹក |
| កាលបរិច្ឆេទនៃការប្រកាសសាលក្រម | ៖ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០២២ |
| សាលសវនាការ និងពេលវេលា | ៖សាលលេខខ១ នៅម៉ោង៩:០០នាទីព្រឹក |

ក្រោមសមាសភាពជំនុំជម្រះ

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ឋានៈចៅក្រម ជាប្រធានក្រុមប្រឹក្សា

លោក [redacted] ឋានៈចៅក្រម ជាចៅក្រមប្រឹក្សា

លោក [redacted] ឋានៈចៅក្រម ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោកស្រី [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូង

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជី សាលាដំបូង

**ដើម្បីជំនុំជម្រះលើ**

សំណុំរឿងព្រហ្មទណ្ឌលេខ ៦៧៥ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ ៖

១/- ឈ្មោះ [redacted] **ទាសនា** ភេទស្រី អាយុ៤៣ឆ្នាំ (កើតថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៧៨) ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តសៀមរាប មានទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តសៀមរាប កម្រិតវប្បធម៌ ថ្នាក់ទី១២ថ្មី មុខរបរលក់បាយ ប្តីឈ្មោះ [redacted] ជាវិទ្ធ (រ) មានកូន៣នាក់ ឪពុកឈ្មោះ [redacted] ឈឿម (ស) ម្តាយឈ្មោះ [redacted] ធួក (រ) ទោសពីមុន គ្មាន។ (ក្រៅឃុំ)

- ដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្នលេខ ៨៩០ ដពស/ឈ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២១

២/- ឈ្មោះ [redacted] **វណ្ណា** ភេទប្រុស អាយុ១៤ឆ្នាំ (កើតថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០៧) ជនជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តសៀមរាប មានលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តសៀមរាប កម្រិតវប្បធម៌ មិនបានរៀន មុខរបរ



Scanned with CamScanner

បុគ្គលិកហាងលក់បាយ នៅលីវ ឪពុកឈ្មោះ [redacted] សុខ (ស) ម្ដាយឈ្មោះ [redacted] ណាង (រ) ទោសពីមុន គ្មាន។ (ក្រៅឃុំ)

- ដីកាបង្គាប់ឲ្យចូលខ្លួនលេខ ៣៧២៥ ពស. ព្រស/ឈ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២១។
- លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិ។

ត្រូវបានបញ្ជូនមកជំនុំជម្រះពីបទ **ធ្វើឲ្យខូចខាតដោយចេតនា** ប្រព្រឹត្តនៅភូមិស្លក្រាម សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤១០ នៃក្រមព្រហ្មទណ្ឌ ។

## ជនរងគ្រោះ និងជាដើមបណ្ដឹងរដ្ឋប្បវេណី

- ឈ្មោះ [redacted] **បូរិន្ទទ័** ភេទប្រុស អាយុ៥៩ឆ្នាំ ជនជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅភូមិស្លក្រាម សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប ។

## អង្គហេតុដែលប្ដឹងមកតុលាការ

កាលពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១ ឈ្មោះ [redacted] វាសនា បានកំពុងវាយលូបង្ហូរទឹករបស់ខ្លួននៅមុខផ្ទះ ស្រាប់តែមានឈ្មោះ [redacted] សេរីគុជ ត្រូវជាកូនរបស់ឈ្មោះ [redacted] បូរិន្ទទ័ ដែលមានព្រំដីជាប់គ្នា បានថតសកម្មភាព ព្រមទាំងបានជេរប្រមាថមកលើឈ្មោះ [redacted] វាសនា ទើបឈ្មោះ [redacted] វាសនា ទ្រាំលែងបាន ក៏បានយកញញួរ ដែលកំពុងវាយលូរបស់ខ្លួនមកវាយព្រះភូមិរបស់ឈ្មោះ [redacted] បូរិន្ទទ័ តែម្ដង។ ហើយក្នុងការវាយកម្ទេចព្រះភូមិនោះ ឈ្មោះ [redacted] វាសនា បានប្រើឲ្យឈ្មោះ [redacted] វណ្ណៈ ដែលជាបុគ្គលិកហាងបាយរបស់ខ្លួនឲ្យជួយវាយកម្ទេចដែរ។

-**បានឃើញ** ពាក្យបណ្ដឹង ចុះថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០២១ របស់ឈ្មោះ [redacted] បូរិន្ទទ័ ។

-**បានឃើញ** របាយការណ៍សំយោគលេខ ៣២/២០២១ នបស្លក្រ ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០២១ របស់ ស្នងការដ្ឋាននគរបាលខេត្តសៀមរាប ។

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ ៧៣០ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តសៀមរាប ។

-**បានឃើញ** ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៤៧៧៨ ពស.ព្រស/ឈ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប ។

-**បានឃើញ** ដីកាចាត់តាំងក្រុមប្រឹក្សាចៅក្រមជំនុំជម្រះលេខ ១០៥ ពស. ព្រជ(ក) ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តសៀមរាប ។

## នាពេលសវនាការ

- ជនជាប់ចោទឈ្មោះ [redacted] វាសនា បានឆ្លើយថា កាលពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១ ខ្លួនពិតជាបានយកញញួរមកវាយព្រះភូមិរបស់ឈ្មោះ [redacted] **បូរិន្ទទ័** ដែលនៅជាប់ព្រំដីជាមួយខ្លួន នៅភូមិស្លក្រាម ដោយមូលហេតុថា ឈ្មោះ [redacted] សេរីគុជ ត្រូវជាកូនរបស់ឈ្មោះ [redacted] បូរិន្ទទ័ បានជេរប្រមាថខ្លួនថា អ្ហែងទៅណាដើរតែរករឿងគេ ហើយអ្ហែងទើបតែមកនៅសោះដើរតែរករឿងគេ អ្ហែងទៅណាសន្សំរឿងគេដែរ អ្ហែងឲ្យតែមានរឿងពូកែប្ដឹងគេណាស់ មានរឿងអីមានបងប្អូនអ្ហែងជួយ អ្ហែងទិញក្បាលអស់ហើយ ក្រោយពីជេរខ្លួនរួចមក ខ្លួនទ្រាំពុំបាននឹងឈ្មោះ [redacted] សេរីគុជ រួចខ្លួនក៏បានវាយព្រះភូមិនោះចោល ដោយព្រះភូមិនោះសាងសង់នៅលើដីមុខផ្ទះរបស់ខ្លួនដែរ។ ខ្លួនពិតជាបានឲ្យឈ្មោះ [redacted] វណ្ណៈ ត្រូវជាបុគ្គលិកហាងឲ្យជួយវាយព្រះ



Scanned with CamScanner

ភូមិនោះមែន ព្រោះខ្លួនវាយតែម្នាក់ឯងហត់ ហើយឈ្មោះ [redacted] វណ្ណៈ ម្ដាយរបស់គាត់យកគាត់ទៅផ្ទះវិញ។ ពីមុនឈ្មោះ [redacted] បូរិន្ទទ័ និងប្រពន្ធរបស់គាត់ឈ្មោះ [redacted] សុខុន តែងតែឈ្លោះប្រកែកជាពាក្យសម្ដីគ្នាជាមួយខ្លួនជាញឹកញាប់។ ខ្លួនធ្លាប់ទៅសម្របសម្រួលនៅប៉ុស្ដិ៍ប៉ូលិស ដោយសុំសងគាត់តែគាត់មិនព្រម។ ព្រះភូមិនោះតម្លៃប្រហែល២៥ (ម្ភៃប្រាំ) ដុល្លារអាមេរិកតែប៉ុណ្ណោះ។

- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] បូរិន្ទទ័ បានឆ្លើយថា ព្រះភូមិដែលខ្លួនសាងសងគឺមានចម្ងាយប្រហែល៧តឹក ពីរបងឈ្មោះ [redacted] វាសនា ។ ហើយព្រះភូមិនោះខ្លួនបានជួលឲ្យគេធ្វើតាំងពីយូរណាស់មកហើយ ខ្លួនមិនបានចាំតម្លៃទេ។ ហើយចំណែកដែលថាកូនប្រុសរបស់ខ្លួនឈ្មោះ [redacted] សេរីគុជ បានជេរប្រមាថឈ្មោះ [redacted] វាសនា គឺមិនពិតទេ ។ ខ្លួនសូមសុំទាមទារសំណងការខូចខាត និងជំងឺចិត្តចំនួន ២.០០០(ពីរពាន់) ដុល្លារអាមេរិក។

- សាក្សីឈ្មោះ [redacted] សេរីគុជ បានឆ្លើយថា កាលពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោង ៩ ព្រឹក ខ្លួនកំពុងតែនៅផ្ទះ ហើយពេលនោះខ្លួនបានឃើញឈ្មោះ [redacted] វាសនា ត្រូវជាមីងរបស់ខ្លួន ដែលផ្ទះជាប់នឹងព្រំដីរបស់ឪពុកខ្លួនឈ្មោះ [redacted] បូរិន្ទទ័ គាត់បានយកប៉ែលមកកាយលូរបស់គាត់នៅជិតព្រះភូមិរបស់ឪពុកខ្លួន បន្ទាប់មកឈ្មោះ [redacted] វាសនា បានឲ្យអ្នកនៅជាមួយគាត់ (មិនស្គាល់ឈ្មោះ) ទៅយកញញួរមកវាយព្រះភូមិរបស់ឪពុកខ្លួន។ ខ្លួននៅមើលចាំថតសកម្មភាពរបស់ឈ្មោះ [redacted] វាសនា ហើយនៅពេលដែលខ្លួនថតនោះ គាត់បានជេរប្រមាថខ្លួន រហូតមានការប៉ះពាក្យសម្ដីជាមួយខ្លួន ស្រាប់តែគាត់យកញញួរវាយព្រះភូមិរបស់ឪពុកតែម្ដង។ ហើយខ្លួនក៏បានថតសកម្មភាពវាយនោះតែម្ដងដែរ។ សំដីខ្លួននិយាយនោះថា មនុស្សសន្សំសុខតែចេះរករឿងឈ្លោះរហូត។ ខ្លួនបានឈ្លោះគ្នាជាមួយគាត់នេះ ជាលើកទីមួយទេ។

- សាក្សីឈ្មោះ [redacted] រង្គ៉ា បានឆ្លើយថា នៅពេលកើតហេតុខ្លួនបានឮសំឡេងឈ្លោះគ្នាខ្លួនក៏ដើរមកមើលក៏បានឃើញប្អូនស្រីរបស់ខ្លួនឈ្មោះ [redacted] វាសនា និងឈ្មោះ [redacted] សេរីគុជ ត្រូវជាក្មួយបានឈ្លោះប្រកែកគ្នា។ ពេលនោះឈ្មោះ [redacted] សេរីគុជ បានប្រើពាក្យមិនគួរសមជេរទៅលើមីងរបស់ខ្លួនឈ្មោះ [redacted] វាសនា ដោយមានពាក្យអ្ហែង ហើយនិងបានជេរថា អ្ហែងចង់បានតែសុខតែចេះតែរករឿងឈ្លោះរហូត បានធ្វើឲ្យឈ្មោះ [redacted] វាសនា ខឹងក៏បានយកញញួរវាយព្រះភូមិតែម្ដង ។

- សាក្សីឈ្មោះ [redacted] បិត ត្រូវជាបងឈ្មោះ [redacted] វាសនា បានឆ្លើយថា ពេលកើតហេតុឈ្មោះ [redacted] សេរីគុជ បាននិយាយដៀមដាមឈ្មោះ [redacted] វាសនា ត្រូវម្ដាយមីងរបស់ខ្លួន ធ្វើឲ្យឈ្មោះ [redacted] វាសនា ខឹងក៏បានយកញញួរវាយព្រះភូមិ ហើយបានហៅអ្នកបម្រើក្នុងហាងមកជួយវាយផងដែរ។

- សាក្សីឈ្មោះ [redacted] ដារិទ្ធ ត្រូវជាប្ដីរបស់ឈ្មោះ [redacted] វាសនា បានឆ្លើយថា ថ្ងៃកើតហេតុមានទំទាស់គ្នារវាង [redacted] សេរីគុជ និងប្រពន្ធរបស់ខ្លួនឈ្មោះ [redacted] វាសនា បានជេរទៅជេរមកហើយប្រពន្ធរបស់ខ្លួនខឹងក៏បានយកញញួរវាយព្រះភូមិ ហើយបានហៅអ្នកបម្រើក្នុងហាងមកជួយវាយដែរ។ តែពេលកើតហេតុនោះខ្លួនមិនបានទៅហាមឃាត់ប្រពន្ធខ្លួនទេព្រោះថ្ងៃនោះខ្លួនកំពុងឈឺ។

- តាមអំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណៈ នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ បានឆ្លើយថា នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១ វេលាម៉ោងប្រហែល៩និង៣០នាទី ខ្លួនកំពុងតែនៅក្នុងហាងបានឮសំឡេងម្ចាស់ហាងឈ្មោះ [redacted] វាសនា ឈ្លោះប្រកែកគ្នា ខ្លួនបានដើរមកមើលកន្លែងឈ្លោះជាមួយបងបង្កើតឈ្មោះ [redacted] បូរិន្ទទ័ ភេទប្រុស អាយុប្រហែល៥០ឆ្នាំ ពេលនោះខ្លួនបានឃើញឈ្មោះ [redacted] វាសនា កំពុងកាន់ញញួរទម្ងន់ប្រហែល៥គីឡូក្រាម វាយទៅលើព្រះភូមិរបស់ឈ្មោះ [redacted] បូរិន្ទទ័ ដែល

នៅខាងមុខហាងជាប់ព្រំដីគ្នា បណ្តាលឲ្យព្រះភូមិធ្លាក់ដល់ដីបែកបាក់ខ្ទេច នៅសល់តែបង្គោលសសរគ្រឹះព្រះភូមិ រួចឈ្មោះ [redacted] វាសនា បានហុចញញួរឲ្យខ្លួន រួចប្រាប់ឲ្យវាយសសរព្រះភូមិនោះកម្ទេចចោល ខ្លួនយកញញួរវាយផង រុញផង រហូតទាល់តែសសរព្រះភូមិនោះបាក់រាបដល់ជើងតាងខាងក្រោម ទើបឈប់វាយ រួចឲ្យខ្លួនទៅក្នុងហាងវិញ ចំណែកឯឈ្មោះ [redacted] វាសនា និងឈ្មោះ [redacted] បូរិន្ទទ៍ នៅឈ្លោះប្រកែកគ្នាមិនដឹងពេលណាចប់ទេ ក្រៅពីនេះខ្លួនមិនបានដឹងអ្វីទៀតឡើយ។ សូមបញ្ជាក់ថា ឈ្មោះ [redacted] វាសនា ជាម្ចាស់ហាងពិតជាបានបញ្ជាឲ្យខ្លួនយកញញួរវាយព្រះភូមិរបស់ឈ្មោះ [redacted] បូរិន្ទទ៍ ពិតប្រាកដមែន ហើយឈ្មោះ [redacted] វាសនា ជាអ្នកវាយមុន និងរួមគ្នាទាំងពីរនាក់។

## សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

ក្រោយពីធ្វើការពិភាក្សា សួរដេញដោលរួចមកឃើញថាជនជាប់ចោទឈ្មោះ [redacted] វាសនា ត្រូវបានមកបញ្ជូនមកជំនុំជម្រះពីបទ **ធ្វើឲ្យខូចខាតដោយចេតនា** ប្រព្រឹត្តនៅភូមិស្លក្រាម សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤១០ **នៃក្រមព្រហ្មទណ្ឌ**។ ឃើញថានៅពេលសវនាការជនជាប់ចោទឈ្មោះ [redacted] វាសនា បានឆ្លើយសារភាពថាខ្លួនពិតជាបានប្រព្រឹត្តអំពើដូចការចោទប្រកាន់ពិតប្រាដកមែន។ ដោយមុនដំបូងដីរបស់ខ្លួនមានដីព្រំជាប់គ្នានឹងដីរបស់ឈ្មោះ [redacted] **បូរិន្ទទ៍** ហើយរហូតដល់ថ្ងៃកើតហេតុឈ្មោះ [redacted] **សេរីគុជ** បានឈ្លោះប្រកែកគ្នាជាមួយឈ្មោះ [redacted] វាសនា និងឈ្មោះ [redacted] វាសនា ខឹងក៏បានយកញញួរវាយព្រះភូមិហើយបានហៅឈ្មោះ [redacted] វណ្ណៈ ដែលជាអ្នកបម្រើនៅក្នុងហាងខ្លួនមកជួយវាយបន្ត។ ឃើញថាឈ្មោះ [redacted] **បូរិន្ទទ៍** ដែលជាដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយថា ហេតុការណ៍ដែលវាយព្រះភូមិនោះខ្លួនមិនបានឃើញផ្ទាល់ទេ គឺកូនប្រុសខ្លួនឈ្មោះ [redacted] **សេរីគុជ** បានថតរូបភាព និងវីដេអូទុក។ ហើយចំពោះព្រំដីនោះខ្លួនមិនបានសាងសង់ខាងដីរបស់ឈ្មោះ [redacted] វាសនា នោះទេគឺខ្លួនបានសាងសង់នៅព្រំដីខ្លួនតែប៉ុណ្ណោះ។ ឃើញថាសាក្សីឈ្មោះ [redacted] **សេរីគុជ** បានឆ្លើយថា នៅថ្ងៃកើតហេតុខ្លួនពិតជាបានឈ្លោះប្រកែកជាមួយឈ្មោះ [redacted] វាសនា ពិតមែន ដោយខ្លួនបានថាឲ្យឈ្មោះ [redacted] វាសនា ថាខ្លួនចង់តែសុខតែចេះរករឿងឈ្លោះរហូត ។ ឃើញថាសាក្សីឈ្មោះ [redacted] **រដ្ឋា** ឈ្មោះ [redacted] **បិត** និងឈ្មោះ [redacted] **ដារិទ្ធ** បានឆ្លើយថា ថ្ងៃកើតហេតុពួកខ្លួនបានឃើញឈ្មោះ **អ៊ុយ សេរីគុជ** និងឈ្មោះ [redacted] វាសនា បានឈ្លោះប្រកែកគ្នា ពេលនោះឈ្មោះ [redacted] វាសនា ខឹងក៏បានយកញញួរវាយព្រះភូមិ ហើយបានហៅឈ្មោះ [redacted] វណ្ណៈ ដែលជាអ្នកបម្រើក្នុងហាងខ្លួនជួយវាយបន្តផងដែរ ។ ក្រោយពីពិភាក្សាដេញដោលនាពេលសវនាការក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងចម្លើយរបស់សាក្សីឃើញថានៅក្នុងសំណុំរឿងនេះ យោងតាមចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងចម្លើយរបស់សាក្សី គឺមានភាពស៊ីសង្វាក់គ្នាជាមួយចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] វាសនា គឺអាចឲ្យយើងជឿបានថាជនជាប់ចោទឈ្មោះ [redacted] វាសនា ពិតជាបានប្រព្រឹត្តដូចការចោទប្រកាន់ពិតប្រាកដមែន។ តំណាងអយ្យការយល់ឃើញថាមានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ ទៅលើជនជាប់ចោទឈ្មោះ [redacted] វាសនា និងឈ្មោះ [redacted] វណ្ណៈ ពីបទ **ធ្វើឲ្យខូចខាតដោយចេតនា** ដូច្នេះតំណាងអយ្យការនៅតែសុំរក្សាការចោទប្រកាន់របស់ខ្លួនទៅលើជនជាប់ចោទទាំងពីរនាក់ ទុកជាបានការដដែល និងសុំឲ្យក្រុមប្រឹក្សាចៅក្រមជំនុំជម្រះផ្តន្ទាទោសជនជាប់ចោទទាំងពីរនេះតាមច្បាប់។



Scanned with CamScanner

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ក្រោយពីធ្វើការពិភាក្សា សួរដេញដោលរួចមកឃើញថាកូនក្តីខ្លួនឈ្មោះ [redacted] វណ្ណៈ មិនមានវត្តមាននាពេលសវនាការនេះទេ តែតាមចម្លើយសារភាពនៅដំណាក់កាលនគរបាលយុត្តិធម៌ បានឆ្លើយថាខ្លួនពិតជាបានវាយព្រះភូមិពិតប្រាកដមែន។ នៅថ្ងៃកើតហេតុកូនក្តីខ្លួនបានឮឈ្មោះ [redacted] វាសនា ឈ្លោះប្រកែកគ្នាជាមួយបងបង្កើតឈ្មោះ [redacted] បូរិន្ទទ័ ពេលនោះ [redacted] វាសនា ខឹងក៏បានយកញញួរមកវាយបំផ្លាញព្រះភូមិនោះ ហើយនៅសល់បន្តិចក៏បានហៅឲ្យកូនក្តីខ្លួនវាយបន្ត ហើយបើយោងតាមចម្លើយរបស់ឈ្មោះ [redacted] វាសនា បានគាត់បានឆ្លើយបញ្ជាក់ថាបានបញ្ជាឲ្យកូនក្តីខ្លួនវាយបន្តដែរ។ នៅក្នុងរឿងនេះពិនិត្យឃើញថាកូនក្តីខ្លួនជាអនីតិជនទើបតែមានអាយុ១៤ឆ្នាំ ហើយជាបុគ្គលិកធ្វើការឲ្យឈ្មោះ [redacted] វាសនា ដែលជាម្ចាស់ហាងនៅពេលម្ចាស់ហាងបញ្ជាឲ្យធ្វើក៏ព្រមធ្វើតាម ហើយមិនបានពិចារណាឲ្យបានគ្រប់គ្រាន់ ហេតុនេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឲ្យឈ្មោះ [redacted] វណ្ណៈ សុំឲ្យចៅក្រមជំនុំជម្រះពិនិត្យសម្រេចអនុវត្តការព្យួរទោសទាំងមូល ដោយសារតែកាលៈទេសៈនៃបទល្មើសដែលស្នាក់នៅជាមួយឈ្មោះ [redacted] វាសនា កូនខ្លួនមិនមានចេតនា និងមិនបានបង្កព្យសនកម្មធ្ងន់ធ្ងរដល់សង្គមឡើយ។

## សំដីចុងក្រោយរបស់ជនជាប់ចោទ

ជនជាប់ចោទឈ្មោះ [redacted] វាសនា សំណូមពរ បើខូចខាតព្រះភូមិសុំសងតម្លៃព្រះភូមិ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វាសនា

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] វណ្ណៈ

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន និងការប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១/- ឈ្មោះ [redacted] វាសនា និងឈ្មោះ [redacted] វណ្ណៈ ត្រូវបានបញ្ជូនមកជំនុំជម្រះពីបទ **ធ្វើឲ្យខូចខាតដោយចេតនា** តាមរយៈដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ **៤៧៧៨ ពស.ព្រស/ឈ** ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តសៀមរាប ពាក់ព័ន្ធនឹងសកម្មភាពវាយព្រះភូមិរបស់ជនរងគ្រោះឈ្មោះ [redacted] **បូរិន្ទទ័** ប្រព្រឹត្តនៅភូមិស្លក្រាម សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញតិមាត្រា៤១០ នៃក្រមព្រហ្មទណ្ឌ ពិតប្រាកដមែន។

២/- ចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] វាសនា មានភាពស៊ីសង្វាក់គ្នាជាមួយ ចម្លើយចំពោះមុខចៅក្រមស៊ើបសួរ អយ្យការ មន្ត្រីនគរបាលយុត្តិធម៌ រួមទាំងស៊ីសង្វាក់ផងដែរជាមួយ របាយការណ៍សំយោគ និងភស្តុតាងនានាដែលកសាងឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ ដែលអាចឲ្យជឿបាន



Scanned with CamScanner

ថា ជនជាប់ចោទពិតជាបានប្រព្រឹត្តបទល្មើស ដូចការបញ្ជូនមកជំនុំជម្រះរបស់ចៅក្រមស៊ើបសួរ ប្រាកដមែន ។

៣/- ជនជាប់ចោទឈ្មោះ [redacted] វាសនា ជានីតិជន ហើយពុំមានសញ្ញាណណាមួយនាំឲ្យមានការសង្ស័យអំពីបញ្ហាស្មារតីឡើយ ដូច្នេះជនជាប់ចោទត្រូវតែទទួលខុសត្រូវខាងព្រហ្មទណ្ឌចំពោះអំពើប្រព្រឹត្តរបស់ខ្លួនត្រឹមកម្រិតច្បាប់បានកំណត់ ។

៤/- ជនជាប់ចោទឈ្មោះ [redacted] វណ្ណៈ ជាអនីតិជន ហើយពុំមានសញ្ញាណណាមួយនាំឲ្យមានការសង្ស័យអំពីបញ្ហាស្មារតីឡើយ ដូច្នេះជនជាប់ចោទត្រូវតែទទួលខុសត្រូវខាងព្រហ្មទណ្ឌចំពោះអំពើប្រព្រឹត្តរបស់ខ្លួនត្រឹមកម្រិតជួនល្មមតាមច្បាប់បានកំណត់ ។

៥/- ជនជាប់ចោទបានធ្វើសកម្មភាពធ្វើឲ្យខូចខាតទ្រព្យសម្បត្តិរបស់អ្នកដទៃ និងខូចខាតប្រយោជន៍ដល់ជនរងគ្រោះ ដែលច្បាប់បញ្ញត្តថាជាបទល្មើស និងត្រូវផ្តន្ទាទោស ។

៦/- អំពើរបស់ជនជាប់ចោទបានប៉ះពាល់ដល់ទ្រព្យសម្បត្តិអ្នកដទៃ សណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខសុវត្ថិភាពសង្គម ។

៧/- សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ នៅតែសុំរក្សាការចោទប្រកាន់របស់ខ្លួន ទៅលើជនជាប់ចោទឈ្មោះ [redacted] វាសនា និងឈ្មោះ [redacted] វណ្ណៈ ទុកជាបានការដដែល និងសុំឲ្យក្រុមប្រឹក្សាចៅក្រមជំនុំជម្រះផ្តន្ទាទោសជនជាប់ចោទទាំងពីរនេះតាមច្បាប់ ដែលគប្បីតុលាការលើកមកពិចារណា ។

៨/- សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] វណ្ណៈ សុំឲ្យចៅក្រមជំនុំជម្រះពិនិត្យសម្រេចអនុវត្តការព្យួរទោសទាំងមូល ដោយសារតែកាលៈទេសៈនៃបទល្មើសដែលស្នាក់នៅជាមួយឈ្មោះ [redacted] វាសនា កូនខ្លួនមិនមានចេតនា និងមិនបានបង្កព្យសនកម្មធ្ងន់ធ្ងរដល់សង្គមឡើយ ដែលគប្បីតុលាការលើកមកពិចារណា ។

៩/- ផ្អែកតាមអង្គហេតុ ភស្តុតាងនានាដែលដាក់បន្ទុក និងចម្លើយរបស់ជនជាប់ទាក់ទិននាពេលសវនាការខាងលើ ឃើញថាអំពើប្រព្រឹត្តរបស់ជនជាប់ចោទរបស់ឈ្មោះ [redacted] វាសនា និងឈ្មោះ [redacted] វណ្ណៈ បានបំពេញជាតុផ្សំគ្រប់គ្រាន់ ពីបទ **ធ្វើឲ្យខូចខាតដោយចេតនា** តាមបញ្ញត្តិមាត្រា៤១០ **នៃក្រមព្រហ្មទណ្ឌ**។

១០/- មានភស្តុតាងលើសពីវិមតិសង្ស័យ និងធាតុផ្សំបទល្មើសគ្រប់គ្រាន់ បង្ហាញថាជនជាប់ចោទឈ្មោះ [redacted] វាសនា ភេទស្រី អាយុ៤៣ឆ្នាំ (កើតថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៧៨) ជនជាតិខ្មែរ សញ្ជាតិខ្មែរ និងឈ្មោះ [redacted] វណ្ណៈ ភេទប្រុស អាយុ១៤ឆ្នាំ (កើតថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០៧) ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានពិរុទ្ធភាពពីបទ **ធ្វើឲ្យខូតខាតដោយចេតនា** ប្រព្រឹត្តនៅភូមិស្លក្រាម សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញតិមាត្រា៤១០ **នៃក្រមព្រហ្មទណ្ឌ**។

១១/- តាមស្ថានភាពរបស់ជនជាប់ចោទ អង្គហេតុ និងបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទឈ្មោះ [redacted] វាសនា ដែលជាបងប្អូនបង្កើតជាមួយដើមបណ្តឹងរដ្ឋប្បវេណី និងទំហំនៃព្យសនកម្ម គប្បីតុលាការពិនិត្យ ពិចារណា សម្រេចផ្តន្ទាទោសលើជនជាប់ចោទទាំងនេះ ដោយឲ្យអនុវត្តការព្យួរទោសធម្មតា។

១២/- ដើមបណ្តឹងរដ្ឋប្បវេណីបានទាមទារសំណងការខូចខាត និងជំងឺចិត្តចំនួន ២.០០០(ពីរពាន់) ដុល្លាអាមេរិក ពីជនជាប់ចោទឈ្មោះ [redacted] វាសនា និងឈ្មោះ [redacted] វណ្ណៈ គប្បីតុលាការលើកយកមកពិចារណា និងសម្រេចទេ តាមព្យសនកម្មជាក់ស្តែងដែលខូចខាត និងភាពសមហេតុសមផល។



Scanned with CamScanner

# សាលាដំបូងខេត្តសៀមរាប

## ហេតុដូច្នេះសម្រេច

១/- ផ្តន្ទាទោសជនជាប់ចោទ ៖

ក/- ឈ្មោះ [redacted] **វាសនា** ភេទស្រី អាយុ៤៥ឆ្នាំ ជនជាតិខ្មែរ (មានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារកំណត់ **៦ (ប្រាំមួយ) ខែ** តែទោសនេះត្រូវអនុវត្តការព្យួរទោសជម្មតា។

ខ/- ឈ្មោះ [redacted] **វណ្ណា** ភេទប្រុស អាយុ១៤ឆ្នាំ ជនជាតិខ្មែរ (មានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារកំណត់ **៣ (បី) ខែ** តែទោសនេះត្រូវអនុវត្តការព្យួរទោសជម្មតា។

ពីបទ **ធ្វើឲ្យខូចខាតដោយចេតនា** ប្រព្រឹត្តនៅភូមិស្លក្រាម សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៤១០ នៃក្រមព្រហ្មទណ្ឌ ។

២/-ឲ្យឈ្មោះ [redacted] **វាសនា** សងសំណងការខូចខាត និងបង់ទឹកប្រាក់នៃជំងឺចិត្តចំនួន **២០០.០០០ (ម្ភៃម៉ឺន) រៀល** ទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **បូរិន្ទ** ។ ការទាមទារលើសពីនេះច្រានចោល ។

សាលក្រមនេះ ជំនុំជម្រះជាអសាធារណៈ នៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] **វាសនា** និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] **វណ្ណា** និងចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **បូរិន្ទ** និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២២។

បើកសិទ្ធិប្តឹងទាស់ និងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |
|---|---|---|
| ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា | ហត្ថលេខា និង ត្រា |

[redacted]

---

"បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃព្រហស្បតិ៍ ៧រោច ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

សៀមរាប ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២២

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សា**

[redacted]



Scanned with CamScanner